ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពត**
សំណុំរឿងរដ្ឋប្បវេណីលេខ:៤១៥
ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០
**សាលក្រមរដ្ឋប្បវេណី**
**លេខ:** ២៣ (ខ)
ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពត**
ប្រកាសសាលក្រម នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២
**ដោយមានសមាសភាពៈ**
**ចៅក្រម**
លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តកំពត
**ក្រឡាបញ្ជី**
កញ្ញា [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពត
ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ៖

-សហដើមចោទឈ្មោះ [redacted] កៅ ភេទប្រុស អាយុ៥១ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] លី ភេទស្រី អាយុ៥០ ឆ្នាំ មានអាសយដ្ឋានភូមិកណ្តាល ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ។

-ចុងចម្លើយឈ្មោះ [redacted] ណាយ ភេទស្រី អាយុ៥០ឆ្នាំ មានអាសយដ្ឋាន [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

**១.ការទាមទាររបស់ដើមចោទ:**

ដើមចោទសុំឱ្យតុលាការចេញសាលក្រមសម្រេចដូចខាងក្រោម៖

-សុំមោឃៈភាពពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ៣១៤ ក/ត ២០១៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០១៤ របស់ឈ្មោះ [redacted] ណាយ ។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី:**

ក្នុងរឿងក្តីនេះសហដើមចោទសុំឱ្យតុលាការចេញសាលក្រមសម្រេចដូចខាងលើ ដោយសុំអោយតុលាការមោឃៈភាពពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ:៣១៤ ក/ត ២០១៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ណាយ និងសុំអោយតុលាការទទួលស្គាល់លើឈ្មោះ [redacted] កៅ និងឈ្មោះ [redacted] លី ជាម្ចាស់សិទ្ធិលើដីនោះ ហើយពាក្យស្នើសុំកាន់កាប់ដីរបស់ចុងចម្លើយកើតចេញពីចេតនាទុច្ចរិតរបស់ចុងចម្លើយ ជាឯកសារដែលកើតឡើងដោយមានវិការៈ និងពុំបានកើតឡើងពីឆន្ទៈពិតប្រាកដរបស់សហដើមចោទឡើយ និងសហដើមចោទឈ្មោះ [redacted] កៅ ជាមនុស្សពិការ(គរថ្លង់) និងពុំចេះអក្សរ ពុំយល់ដឹងអំពីអត្ថន័យខ្លឹមសារនៃពាក្យស្នើសុំកាន់កាប់ដីដែលចុងចម្លើយបានអោយសហដើមចោទឈ្មោះ [redacted] កៅ ផ្តិតមេដៃលើឯកសារពាក្យស្នើសុំកាន់កាប់ដី។ ហើយការដាក់ពាក្យស្នើសុំកាន់កាប់ដីរបស់ចុងចម្លើយខុសទំហំដីនិងព្រំប្រទល់ ជាក់ស្តែងពុំមានផ្លាស់ប្តូរអ្នកជាប់ព្រំដូចជាការអះអាង និងក្នុងពាក្យស្នើសុំកាន់កាប់ដីរបស់ចុងចម្លើយឈ្មោះ [redacted] ណាយ ឡើយ ។

## សំអាងហេតុ

តាមការអះអាងរបស់សហដើមចោទដូចមាននៅក្នុងពាក្យបណ្តឹងឃើញថា៖

Scanned with CamScanner

១.ការទាមទាររបស់សហដើមចោទអោយតុលាការចេញសាលក្រមមោឃៈភាពលើពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ:៣១៤ ក/ត ២០១៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ណាយ និងសុំអោយតុលាការទទួលស្គាល់សហដើមចោទឈ្មោះ [redacted]កៅ និងឈ្មោះ [redacted]លី ជាម្ចាស់កម្មសិទ្ធិលើដី ព្រមទាំងសុំអោយចុងចម្លើយសងសំណងការខូចខាតចំនួន ១០លានរៀល ។ ចុងចម្លើយឈ្មោះ [redacted] ណាយ បានអះអាងថាខ្លួនមិនទទួលស្គាល់លើការទាមទាររបស់សហដើមចោទឡើយ ដោយមូលហេតុថារឿងក្តីពាក់ពន្ធនិងដីនេះបានចប់សព្វគ្រប់ដោយមានសាលក្រមលេខ:៤៥ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពត, សាលដីកាលេខ:២៩ ក្រV(សស)ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ, សាលដីកាលេខ:៤៥ (ច) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ របស់តុលាកាកំពូល ។

២.តាមសាលក្រមលេខ:៤៥(ច) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ទទួលស្គាល់ឈ្មោះ [redacted]ណាយ មានសិទ្ធិលើដីតាមពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ:៣១៤ ក/ត ២០១៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងសំអាងហេតុត្រង់ចំណុចទី៣ នៃសាលដីកាលេខ:២៩ ក្រV (សស) ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ មានខ្លឹមសារទទួលស្គាល់ពាក្យសុំកាន់កាប់ដីចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ ដែលមានឈ្មោះ [redacted] កៅ ព្រមព្រៀងផ្តិតមេដៃលើលិខិតនេះ ហើយសាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមលេខ:៤៥(ច) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពត។ ជាងនេះទៅទៀតនៅក្នុងសំអាងហេតុងត្រង់ចំណុចទី៤ តុលាការកំពូលយល់ឃើញថា ការអះអាងអំពីវិការៈក្នុងពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ គឺតុលាការកំពូលមិនអាចទទួលយកបានដែរ ព្រោះពាក្យសុំកាន់កាប់ដីប្រើប្រាស់ដីធ្លី មិនមែនជាកិច្ចសន្យាទេ ហើយឈ្មោះ [redacted] កៅ ផ្តិតមេដៃក្នុងនាមជាសាក្សីដឹងឮ មិនមែនជាការផ្តិតមេដៃក្នុងនាមជាគូភាគីដែលត្រូវលើកយកបញ្ហាវិការៈមកពិចារណាឡើយ។

ដូច្នេះអង្គហេតុដែលដើមចោទបានលើកឡើងត្រូវបានតុលាការវិនិច្ឆ័យនិងសម្រេចជាស្ថាពរដែលមានអាជ្ញាអស់ជំនុំលក្ខណៈសារធាតុហើយ ដូចនេះការទាមទាររបស់ដើមចោទគ្មានផលប្រយោជន៍នៃបណ្តឹងឡើយ គប្បីតុលាការលើកចោលតាមមាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៣.ប្រាក់ប្រដាប់ក្តីអនុវត្តតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

**១.**លើកចោលពាក្យបណ្តឹងរបស់សហដើមចោទតាមបញ្ញត្តិមាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**២.**ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហដើមចោទ ។

ថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកំពត,ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និងត្រា៖ [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកំពត,ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner